# អាជ្ញាធរខេត្តអំពាវនាវផងព្រមានផងចំពោះបញ្ហាបរិស្ថាន

កំពង់ឆ្នាំង : បរិស្ថានល្អ គឺជាប្រភពនៃសុខភាពរបស់ប្រជាពលរដ្ឋ កិច្ចគាំពារបរិស្ថានជាចំណែកមួយមិនអាចខ្វះបានក្នុងការរួមចំណែកគាំពារ និងអភិវឌ្ឍន៍ប្រទេសជាតិ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរជាងមុន ។ នេះគឺជាប្រសាសន៍របស់លោកឈួច ម៉ារីម អភិបាលខេត្តកំពង់ឆ្នាំង បានថ្លែងក្នុងទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ដែលបានប្រារព្ធធ្វើនៅភូមិសំរោង ឃុំផ្សារឆ្នាំង ស្រុកកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី៥មិថុនា ។



លោកឈួច ម៉ារីម និងកញ្ញាផោក សុទ្ធា ដាំកូនឈើក្នុងទិវាបរិស្ថាន (រូបថតសហការី)

លោកអភិបាលខេត្ត បានធ្វើការអំពាវនាវថា មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន កុំបោះបង់សំរាមនិងកាកសំណល់ផ្សេងៗនៅក្នុងទន្លេ បឹងបួ និងនៅតាមទីសាធារណៈនានា ដោយត្រូវវេចខ្ចប់ទុកដាក់ឱ្យបានត្រឹមត្រូវ ។ បើធ្វើបានដូចនេះ មានន័យថាយើងពិតជាបានរួមចំណែកក្នុងការថែរក្សាអនាម័យ និងការពារបរិស្ថានឱ្យមាននិរន្តរភាព។

លោកឈួច ម៉ារីម ក៏បានធ្វើការអំពាវនាវផងដែរថា គ្រប់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់ថ្នាក់ សមត្ថកិច្ចគ្រប់ផ្នែកទាំងអស់ ត្រូវបន្តប្រឹងប្រែងថែមទៀត ដើម្បីទប់ស្កាត់ឱ្យបាននូវរាល់ការបំផ្លិចបំផ្លាញធនធានធម្មជាតិ ពិសេសការកាប់គាស់រានដីព្រៃឈើ ព្រៃលិចទឹក ដោយក្រុមជនល្មើសណាក៏ដោយ ដែលបានធ្វើសកម្មភាពបំពារបំពានយកដីរបស់រដ្ឋធ្វើជាកម្មសិទ្ធិ ។ ចំពោះអ្នកប្រព្រឹត្តល្មើសទាំងឡាយ ត្រូវបញ្ឈប់សកម្មភាពរបស់ខ្លួនជាបន្ទាន់ ហើយប្រគល់ដីដែលបានបំពាននោះយកមកប្រគល់ជូនរដ្ឋវិញ ដើម្បីជៀសវាងការប្រឈមនឹងច្បាប់ ។

កញ្ញា ផោក សុទ្ធា ប្រធានមន្ទីរបរិស្ថានខេត្តកំពង់ឆ្នាំងបានមានប្រសាសន៍ថា ទិវាបរិស្ថានដែលប្រារព្ធធ្វើឡើងនាពេលនេះក្នុងគោលបំណងពញ្ញាក់ស្មារតីជនគ្រប់រូបឱ្យគិតគូរពីបញ្ហាបរិស្ថាននិងជួយដាស់តឿនដល់សហគមន៍ជាតិទាំងមូលឱ្យយកចិត្តទុកដាក់ពីបញ្ហាបរិស្ថាននេះ ដើម្បីផលប្រយោជន៍សម្រាប់មនុស្សគ្រប់រូប គ្រប់គ្រួសារនិងសង្គមជាតិទាំងមូល ។ កញ្ញាប្រធានមន្ទីរបានបញ្ជាក់ឱ្យដឹងថា ទិវាបរិស្ថានឆ្នាំនេះយើងចាប់អារម្មណ៍ជាចម្បងទៅលើការប្រែប្រួលអាកាសធាតុ ដោយកម្មវិធីបរិស្ថានសហប្រជាជាតិបានដាក់ចេញនូវប្រធានបទមួយថ្មីថា «ការរលាយទឹកកកនៅតំបន់ប៉ូល ជាប្រធានបទដ៏ក្តៅគគុក» ។

សខសត្ថា

ឆ្នាំទី១៥ លេខ៤៣០៥ ថ្ងៃសុក្រ ទី០៨ ខែមិថុនា ឆ្នាំ២០០៧